សារព័ត៌មាន
# ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ
ឆ្នាំទី០២ លេខ២៣៣ ចេញផ្សាយថ្ងៃ សៅរ៍ ទី ៣០ ខែ សីហា ឆ្នាំ ២០០៨

## ម៉ែន សំអន ចង់បានតំណែងជារដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី របស់ សុខ អាន



លោកស្រី ម៉ែន សំអន រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងសភា ព្រឹទ្ធសភា



លោក សុខ អាន ជន្លង ហ៊ុន សែន

ដោយ : ស្សាទរីយ៍

លោកស្រី *ម៉ែន សំអន* រដ្ឋមន្ត្រីក្រសួង ទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ចនៃរដ្ឋាភិបាលអាណត្តិ៣ បានតវ៉ាជាមួយ លោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* យ៉ាងខ្លាំង ដើម្បីដណ្តើមយកតំណែង ជារដ្ឋមន្ត្រីទទួល

តទៅទំព័រ២ ស

## សៀមមើលងាយរដ្ឋាភិបាលកញ្ឆប់ផល់មេដំបូល



អ្នកនាំពាក្យ ផៃ ស៊ីផាន



តេជ ប៊ុនណាក រដ្ឋមន្ត្រីការបរទេសសៀម និងកុងស៊ុយ ហោ ណាំហុង

ដោយ : គ.អរពិន្ទ

បើទោះបីជាមានការចេញបកស្រាយដោយមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល*ហ៊ុន សែន* ជំនួសរដ្ឋាភិបាលសៀមអំពីដំណឹងដែលខាងភាគីសៀមប្រាប់មកកម្ពុជាឱ្យផ្អាកការប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសលើកទី៣គ្រោងធ្វើ

តទៅទំព័រ២ ឈ

## បុរសខ្លាំងរុញច្រង់ នរោត្តម រណឫទ្ធិ អោយទ័លច្រក និងបង្ខំឱ្យសោយព្រះកំហាកខ្លួនឯង



ទ្រង់ នរោត្តម រណឫទ្ធិ មេបក្សដ៏មហាយ៉ាប់ និងមន្ត្រីខ្សោមខ្សឹម

ដោយ: សច្ចៈ

លោក*ហ៊ុន សែន* អនុប្រធានគណបក្សប្រជាជន បានស្នើសម្តេចក្រុមព្រះអោយមកធ្វើជាប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិចវិញ ជាថ្នូរនឹងការស្នើសុំប្រប្រទាន ការលើកលែងទោសថ្វាយព្រះអង្គ និងទទួលបានតំ

តទៅទំព័រ២ គ

## សម រង្ស៊ី : ប្រទេសជាហត្ថលេខីនៃកិច្ចព្រមព្រៀងក្រុងប៉ារីសត្រូវតែស្វែងរកដំណោះស្រាយចំពោះការបោះឆ្នោតមិនប្រក្រតីនេះ



លោក សម រង្ស៊ី ប្រធានគណបក្សសមរង្ស៊ី



លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស



ប្រជាពលរដ្ឋដែលមិនបានបោះឆ្នោតកំពុងធ្វើការទាមទារយ៉ាងសកម្ម




ទិដ្ឋភាពនៃកិច្ចប្រជុំសន្តិសីទក្រុងប៉ារីស ២៣ តុលា ១៩៩១

ដោយ : មាន្យ ឧត្តម

លោក *សម រង្ស៊ី* ប្រធានគណបក្សសមរង្ស៊ីបានសម្តែងនូវការខកចិត្តយ៉ាងខ្លាំងចំពោះការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃប្រទេសកម្ពុជាដែលបានច្រានចោលពាក្យបណ្តឹងរបស់គណបក្សសមរង្ស៊ី និងបិទផ្លូវតវ៉ាទៀត។ ចំណែកគណបក្សសិទ្ធិមនុស្សរបស់លោក *កឹម សុខា* ដែល

តទៅទំព័រ៤ ម

## អង្គការសមាគមខ្មែរកម្ពុជាក្រោមស្នើសុំការអនុញ្ញាតពីស្ថានទូតយួនទៅសួរសុខទុក្ខលោក ទឹម សាខន



លោក ថាច់ សេដ្ឋា



លោក ទឹម សាខន



អតីតព្រះសង្ឃខ្មែរកម្ពុជាក្រោមដែលត្រូវតុលាការយួនកាត់ទោសកន្លងមក

ដោយ : ទិសាល

សហគមន៍ខ្មែរកម្ពុជាក្រោមដែលដឹកនាំដោយលោក*ថាច់ សេដ្ឋា*ក៏ដូចជាអង្គការសមាគមខ្មែរកម្ពុជាក្រោមមួយចំនួនទៀតកំពុងតែរង់ចាំទទួលចម្លើយពីស្ថានទូតយួនប្រចាំក្រុងភ្នំពេញ ដើម្បីបានទៅសួរសុខទុក្ខលោក *ទឹម សាខន* ដែលកំពុងមានជំងឺជាទម្ងន់ និងកំពុងតែរស់នៅដោយគ្មានសេរីភាពពិតប្រាកដ

តទៅទំព័រ៤ យ

*ទស្សនៈមិត្តអ្នកអាន*

## ស៊ីតឹតឈ្មុះឆ្នោតនាំងព្រលឹងចុងសក់

អ្វីៗពេលនេះដូចប្រជារាស្ត្រខ្មែរឃើញស្រាប់គ្រប់គ្នាហើយថា បើទោះបីជាគណបក្សប្រជាជន *ហ៊ុន សែន* មានគណៈកម្មាធិការរៀបចំការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ខេត្តក្រុង ឃុំសង្កាត់ឃុបឃិតជាមួយអាជ្ញាធរដែនដីគណបក្សប្រជាជនលួចសន្លឹកឆ្នោតប្រជារាស្ត្រផង ប្លន់យកសន្លឹកឆ្នោតប្រជារាស្ត្រផងបំភ្លៃ

តទៅទំព័រ៣ ហ

## ទូរទស្សន៍សៀមសរសើរ ហ៊ុន សែន ថាវីរបុរសដែលអត់ធ្មត់ឱ្យទាហានសៀមឈ្លានពាន



ទិដ្ឋភាពនៃកងទ័ពសៀមឈ្លានពានកំពុងចល័តនឹកន្លែងក្បែរប្រាសាទព្រះវិហារ



នាយករដ្ឋមន្ត្រី ហ៊ុន សែន

ដោយ : រតនៈ

គិតត្រឹមថ្ងៃនេះ គឺចំនួន៤៦ថ្ងៃហើយ ដែលទាហានឈ្លានពានសៀមទន្ទ្រាន ចូលបូរណភាពទឹកដីខ្មែរ ។ ទាហានចោរសៀមទាំងនោះបានឈ្លានពានចូលដីខ្មែរជាលើកដំបូង នៅថ្ងៃទី១៥ កក្កដា ២០០៨ ដែល

តទៅទំព័រ៣ ជ

ស្រូវទុំ កំរងកែវ

ភោជនីយដ្ឋាន **កំរងកែវ** អតីតភោជនីយដ្ឋាន **ស្រូវទុំ** ឥឡូវនេះបានបើកឡើងវិញហើយ ដោយប្តូរឈ្មោះថា **កំរងកែវ** ដោយប្តូរទាំងចៅកែ ។

លោក មាស គន្ធី ដែលជាអតីតចៅកែភោជនីយដ្ឋាន **ស្រូវទុំ** ត្រូវបានផ្លាស់ប្តូរដោយចៅកែថ្មីដែលមានជំនាញពិសេសល្អលើសចៅកែចាស់ (ស្រូវទុំ) ទ្វេដង ពីព្រោះចៅកែថ្មី និងចុងភៅសុទ្ធតែមានបទពិសោធយូរឆ្នាំ និងមានជំនាញច្បាស់លាស់ ។

អាស្រ័យហេតុនេះ សូមអញ្ជើញភ្ញៀវទាំងអស់មកភ្លក្សរស់ជាតិដែលជាស្នាដៃរបស់ចៅកែ និងចុងភៅថ្មី និងមានការរៀបចំយ៉ាងពិសេសសម្រាប់ភ្ញៀវទាំងអស់ដែលបានអញ្ជើញមកពិសានៅភោជនីយដ្ឋានយើងខ្ញុំ ។

**បញ្ជាក់** : ចំពោះភ្ញៀវដែលអញ្ជើញមកពិសានៅភោជនីយដ្ឋាន **កំរងកែវ** យើងខ្ញុំដោយភ្ជាប់ជាមួយនឹងប័ណ្ណជូនដំណឹងក្នុងសារព័ត៌មានខ្មែរម្ចាស់ស្រុកនេះ យើងខ្ញុំនឹងបញ្ចុះតម្លៃជូន១០% ។

អាស័យដ្ឋាន ផ្ទះលេខ៤២ ផ្លូវ២៨៩ កែងសាលាទួលគោក "ពៅអ៊ុំ"

## ដំណឹងពិសេសដ៏អស្ចារ្យ

ពីលោកគ្រូ **ហោ លីម** ព្យាបាលតាមរបៀបម៉ាស្សា លាប រឹត ស្អំ ថ្នាំបុរាណខ្មែរ ធូរស្បើយក្នុង រយៈពេល **១ម៉ោង (មិនធូរស្បើយមិនគិតលុយ)** នូវជំងឺមនុស្សចាស់ ចុកចាប់ក្នុងរាងកាយ, ឈឺក្បាលជាយូរឆ្នាំក្តី, ឈឺជង្គង់, ឈឺសន្លាក់ដៃ សន្លាក់ជើង, រោយឆ្អឹងខ្នង, តឹងច្រមុះ, តឹងទ្រូង, ថប់ដង្ហើម, ញ័រទ្រូង, ទល់ឆ្អល់ក្នុងពោះ, ពិបាកបត់ជើងតូចធំ, ជាពិសេសជំងឺ១០០មុខក្នុង រាងកាយ ។ល។ **ផ្នែកសម្រស់ :** សង្វាពោះក្រាស់ ជាំមុខ គ្មានដោះ ឬដោះស្ប៉ត ព្យាបាល យ៉ាងស័ក្តិសិទ្ធិ។

ទីតាំងផ្ទះលេខ០៧៧ **ហោ លីម ថែសម្ផស្ស** ច្រកចូលផ្លូវមានដំបូល ជាប់របងស្តាតចាស់ សង្កាត់ស្រះចក ខណ្ឌដូនពេញ

ទូរស័ព្ទទំនាក់ទំនង : **012 363 331, 016 719 616, 012 801 863, 016 719 613**

*បរិយាយថ្ងៃនេះ*

## រដ្ឋាភិបាលហ៊ុនសែនអាណត្តិទី៤ សាកល្បងក្លងទិសដៅ ទៅរកបបផ្តាច់ការបែបត្ងមាឬ ?

ដោយ : មាន្យ ប្រាជ្ញា

ថ្មីៗនេះ អ្នកនយោបាយជាន់ខ្ពស់ម្នាក់របស់គណបក្សប្រជាជនដែលគឺជាអ្នកមានជាន់ថ្មីមានជីវភាពជាសេដ្ឋីបាននិយាយថា សម្រាប់អាណត្តិទី៤នេះ អំណាចទាំងអស់នឹងប្រមូលផ្តុំទៅលើគណបក្សប្រជាជន ហើយដូច្នេះគណបក្សប្រជាជននឹងធ្វើការសាកល្បងដឹកនាំប្រទេសដោយខ្លួនឯង។

តទៅទំព័រ៤ ក

**តមកពីទំព័រ១ ឈ**

កាលពីម្សិលមិញថា មកពីមានមូលហេតុនៃការវឹកវរនយោបាយនៅទីក្រុងបាងកកនោះក៏ដោយ ក៏ការឆ្លើយបំភ្លឺនេះនៅតែមិនអាចជម្រះកេរ្តិ៍ឈ្មោះរបស់រដ្ឋាភិបាល *ហ៊ុន សែន* បានទេ។ រដ្ឋាភិបាលកម្ពុជា នៃគណបក្សប្រជាជន *ហ៊ុន សែន* កំពុងភ្ជាប់ឈ្មោះឱ្យគេមើលឃើញយ៉ាងច្បាស់ថា ត្រូវរដ្ឋាភិបាលសៀមមើលងាយដល់មេដំបូល។

ទាំងមន្ត្រីជាន់ខ្ពស់នៃក្រសួងការពារប្រទេសរបស់រដ្ឋាភិបាល *ហ៊ុន សែន* ទាំងមន្ត្រីនៃទីស្ដីការគណៈរដ្ឋមន្ត្រីរបស់រដ្ឋាភិបាលគណបក្សប្រជាជននេះបានខំនិយាយដោះសារជំនួសសៀមថាមកពីមានមូលហេតុនៃបាតុកម្មមហាជនដ៏ធំប្រឆាំងនឹងរដ្ឋាភិបាលសៀមនៅក្រុងបាងកកទើបបានជាមានការលើកពេលនៃគម្រោងប្រជុំកាលពីថ្ងៃសុក្រទី២៩ ខែសីហា ម្សិលមិញ។

ហើយដើម្បីជាការនិយាយជំនួសសៀមទាំងសៀមពុំបានផ្ដល់ព័ត៌មានអ្វីឱ្យច្បាស់លាស់ដើម្បីឱ្យមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាល *ហ៊ុន សែន* បកស្រាយប្រាប់សាធារណៈមតិនោះ មន្ត្រីជាន់ខ្ពស់កម្ពុជាគណបក្សប្រជាជន *ហ៊ុនសែន*បាននិយាយថាសៀមបានបញ្ជូនមន្ត្រីរបស់ខ្លួនប្រមាណ៣០នាក់ឱ្យចូលមកកម្ពុជាកាលពីថ្ងៃពុធដើម្បីត្រៀមប្រជុំតាមគម្រោងនោះ ហើយទើបតែនឹងដកទៅវិញក្រោយពីមានដំណឹងពីក្រុងបាងកក។

ប៉ុន្តែពួកអ្នកសង្កេតការណ៍ទាំងប្រជារាស្ត្រខ្មែរមើលឃើញយ៉ាងច្បាស់ថានេះជាការប្រមាថដោយចេញមុខរបស់រដ្ឋាភិបាលសៀមមួយទៀតមកលើរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* ។ ខាងសៀមគ្រាន់តែប្រាប់ដំណឹងមកឱ្យមន្ត្រីបុគ្គលិករបស់ខ្លួនរៀបចំសម្ភារៈវិលត្រឡប់ទៅក្រុងបាងកកវិញប៉ុណ្ណោះ។ ពុំមានមូលហេតុច្បាស់លាស់ណាមួយត្រូវខាងរដ្ឋាភិបាលសៀមប្រាប់បញ្ជាក់ឱ្យរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* នោះទេ។

លើសពីនេះទៅទៀតសៀមក៏គ្រាន់តែបាននិយាយអំពីការលើកពេលក៏ប៉ុន្តែមិនបាននិយាយអំពីការដាក់កាលកំណត់ច្បាស់លាស់នៃការប្រជុំដែលលើកពេលពីថ្ងៃទី២៩ ខែសីហា ដល់ពេលណានោះឡើយ។

ម្ដងនេះទៀតអ្វីៗក៏លេចធ្លាយចេញយ៉ាងច្បាស់ថាសៀមបាននឹងកំពុងប្រើល្បិចនៃរបស់ដែលហៅថា ការចរចាទ្វេភាគីផ្នែកការទូត គ្រាន់តែដើម្បីបិទបាំងផែនការយុទ្ធសាស្ត្រនៃការប្រើកម្លាំងយោធារបស់ខ្លួនឱ្យឈ្លានពានចូលកាន់កាប់កម្ពុជាតាមបណ្ដោយព្រំដែនតែប៉ុណ្ណោះ។

តាមគម្រោងដើមនៃការប្រជុំថ្ងៃ២៩ ខែសីហា ដែលបានក្លាយជាការខកខានពុំមានដំណឹងអ្វីច្បាស់លាស់ និងគ្មានការកំណត់ពេលនោះភាគីរដ្ឋាភិបាលសៀម និងរដ្ឋាភិបាល *ហ៊ុន សែន* មានបំណងនឹងនិយាយជជែកគ្នាអំពីការកំណត់ពេលវេលាដើម្បីនឹងកាត់បន្ថយចំនួនកងទាហានទាំងសង្ខាងនៅតំបន់មានជម្លោះ ជាពិសេសនៅវត្តកែវសិក្ខាគីរីស្វារៈឬវត្តប្រាសាទព្រះវិហារ។

ការលើកពេលនេះរបស់សៀមទោះបីជាដោយលើកមូលហេតុនៃរបស់ដែលហៅថា ការជ្រួលច្របល់នៃនយោបាយនៅក្រុងបាងកកដោយមានបាតុកម្មទាមទារឱ្យនាយករដ្ឋមន្ត្រីសៀម *សាម៉ាក់ ស៊ុនដារ៉ាវេត* ចុះចេញពីតំណែងនោះ ក៏យ៉ាងណាវាមានលក្ខណៈជាផ្នែកនៃយុទ្ធវិធីការទូតរបស់សៀមគ្របសង្កត់យកប្រៀបលើរដ្ឋាភិបាល *ហ៊ុន សែន* អំពីបញ្ហានៃការប្រឈមមុខផ្នែកយោធាដាក់គ្នារវាងកងទាហានប្រទេសទាំងពីរនោះ។

នោះក៏ព្រោះថា គម្រោងនៃការជួបគ្នាថ្ងៃទី២៩ សីហា មានត្រឹមតែការលើកនិយាយអំពីការដកទាហានទាំងសង្ខាងឱ្យនៅសល់ចំនួនតិចនៅវត្តកែវសិក្ខាគីរីស្វារៈ។ពុំមែនភាគីទាំងពីរត្រូវជជែកគ្នាអំពីការដកទាហានសៀមចេញពីទឹកដីនៃតំបន់តាមព្រំដែនដទៃទៀតដែលសៀមបានលើកគ្នាមកចូលកាន់កាប់ដូចនៅប្រាសាទតាមាន់ធំក្នុងស្រុកបន្ទាយអំពិល ខេត្តឧត្ដរមានជ័យរបស់កម្ពុជានោះផងទេ។

ចង់ឬមិនចង់ទោះជាដោយហេតុផលយ៉ាងណាក៏ដោយ ឥរិយាបថរបស់សៀមលើកពេលដោយមិនប្រាប់មូលហេតុ និងគ្មានការកំណត់ពេលច្បាស់លាស់ពីជំនួបចរចាទ្វេភាគីលើកក្រោយនោះវាមិនមែនត្រឹមតែជាការបង្ហាញឱ្យឃើញនូវភាពមិនស្មោះត្រង់របស់សៀមចំពោះរដ្ឋាភិបាលកម្ពុជានោះទេ ប៉ុន្តែក៏ជាការប្រាប់ឱ្យដឹងអំពីអកប្បកិរិយាមើលងាយប្រមាថរដ្ឋាភិបាល *ហ៊ុន សែន* ផងដែរក្នុងដំណើររឿងនេះ។

ទន្ទឹមនឹងនេះទៀត ពេលដែលសៀមត្រូវគេមើលឃើញថាប្រើឧបាយលយករបស់ដែលហៅថា ការចរចាផ្នែកទូតត្រឹមតែទ្វេភាគី ជុំវិញសៀមលើកទាហានចូលកាន់កាប់ដីខ្មែរតាមតំបន់ព្រំដែននោះ ក៏សៀមនៅតែបានប្រើកលល្បិចបញ្ជូនទាហានរបស់ខ្លួនដាក់ពង្រាយកាន់កាប់ទឹកដីខ្មែរច្រើនកន្លែងទៀតតាមបណ្ដោយព្រំដែន។

អ្វីដែលគេមើលឃើញថាជានយោបាយការទូតលាក់កន្ទុយរបស់សៀមបាំងភ្នែករដ្ឋាភិបាល *ហ៊ុន សែន*គឺត្រង់សៀមនិយាយអំពីការដកទាហានរបស់ខ្លួនចេញពីទឹកដីកម្ពុជាជារបៀបនៃការផ្លាស់ប្ដូរកម្លាំង។ ប៉ុន្តែបើនិយាយឱ្យពិតប្រាកដទៅវាជាយុទ្ធសាស្ត្រ នៃការបង្កើនចំនួនយោធាសៀមនៅលើទឹកដីខ្មែរ ពីព្រោះជាមួយការដោះដូរកម្លាំងនោះសៀមបានដាក់កម្លាំងមកថ្មីច្រើនលើសពីកម្លាំងដូរដូចគេឃើញទាហានសៀមមានចំនួនកាន់តែច្រើនឡើងៗនៅតំបន់ដែលសៀមចូលកាន់កាប់ទឹកដីខ្មែរហើយនៅមិនទាន់មានការដកថយទៅវិញរៀងៗខ្លួននោះ។

ខាងរដ្ឋាភិបាល *ហ៊ុន សែន* វិញហាក់បីដូចជាដឹងខ្លួនថាចាញ់បោកល្បែងនយោបាយការទូតរបស់សៀម ម្ដងហើយ ម្ដងទៀត បន្ថែមពីលើការចាញ់ប្រៀបសៀមដែលហ៊ានបញ្ជូនកងទ័ពប្រដាប់អាវុធរបស់ខ្លួនឆ្លងដែនចូលកាន់កាប់កម្ពុជាហើយប្រកាសថាជាទឹកដីរបស់សៀមទាំងមេដឹកនាំរដ្ឋាភិបាល *ហ៊ុន សែន* ក៏ដូចជាមេទ័ព *ហ៊ុន សែន* មិនហ៊ានចាត់វិធានការក្នុងនាមកម្ពុជាជាម្ចាស់ទឹកដីដើម្បីរារាំងការចូលឈ្លានពានរបស់ទាហានសៀមមកក្នុងទឹកដីខ្មែរនោះទេ។

ឯអ្នកនាំពាក្យនៃទីស្ដីការគណៈរដ្ឋមន្ត្រីរបស់រដ្ឋាភិបាល *ហ៊ុនសែន*វិញបានលើកនិយាយនូវភាសាដដែលៗ ដែលគេមិនសូវជឿនិងមិនមានប្រសិទ្ធភាពក្នុងការដោះសារ ដោយថា ការចរចាថ្នាក់ការទូតទ្វេភាគី គឺជាបែបបទការងារតាមនីតិវិធីផ្ទៃក្នុងអាស៊ាន ឬមុននឹងមានការលើកបញ្ហាទៅដល់ថ្នាក់អន្តរជាតិណានោះ។ ពិតជាត្រឹមត្រូវហើយពេលដែលមានការនិយាយអំពីការចរចាការទូតដើម្បីបន្ថយនូវការប្រឈមមុខដាក់គ្នាដែលអាចផ្ទុះជាសង្គ្រាមបាននោះ។

ប៉ុន្តែវាដូចជាសេចក្ដីសារភាពរបស់រដ្ឋាភិបាល *ហ៊ុន សែន* ផងដែរ ពេលដែលអ្នកនាំពាក្យនៃទីស្ដីការគណៈរដ្ឋមន្ត្រីបាននិយាយក្នុងបទសម្ភាសន៍ជាមួយវិទ្យុបរទេសមួយ ទទួលស្គាល់ថាការលើកពេលអូសបន្លាយដោយកលល្បិចណាមួយរបស់សៀមតាមបែបការប្រជុំទ្វេភាគីយ៉ាងនេះ អាចប៉ះពាល់ដល់ការនាំទៅដល់កិច្ចប្រជុំពហុភាគី។

*ផៃ ស៊ីផាន* បាននិយាយអំពីរឿងនេះដូចជាដឹងខ្លួនថាអ្វីៗដែលរដ្ឋាភិបាលគណបក្សប្រជាជនបានធ្វើកន្លងមក គឺជាកំហុសព្រោះតែខាតពេលវេលាចាញ់បោកសៀមយ៉ាងស្រស់ៗ។ នោះគឺ *ផៃ ស៊ីផាន* បាននិយាយអំពីលទ្ធភាពនៃការយកបញ្ហាទៅដោះស្រាយក្នុងកិច្ចចរចាពហុភាគីដូចជាតាមរយៈក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលនេះជាអនុសាសន៍ពីដំបូងទីរបស់មន្ត្រីអង្គការសង្គមស៊ីវិលនិងមន្ត្រីជំនាញទាំងឡាយហើយដែលរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* មិនខ្វីស្ដាប់នោះ។

យ៉ាងណាក៏ដោយ ពាក្យរបស់ *ផៃ ស៊ីផាន* និយាយអំពីការចរចាទ្វេភាគីខ្មែរ-សៀម ជាដំណោះស្រាយតាមមធ្យោបាយការទូតថា "*យើងធ្វើឱ្យគេដឹង ធ្វើឱ្យគេយល់ ធ្វើឱ្យគេជឿ និងធ្វើឱ្យគេគាំទ្រ*" នេះគ្រាន់តែជាពាក្យដោះសារមួយបែបទៀតបិទបាំងនូវកំហុសយុទ្ធសាស្ត្រការទូតដ៏ធំដែលរដ្ឋាភិបាល *ហ៊ុន សែន* បានប្រកាន់យក ហើយត្រូវគេមើលឃើញថា ជាការបណ្ដោយខ្លួនឱ្យចាញ់បោកល្បែងការទូតរបស់សៀមយ៉ាងងាយៗ ម្ដងហើយ ម្ដងទៀតដើម្បីអ្វីដែលសៀមគិតថាធ្វើយ៉ាងនេះអាចបិទបាំងបំភ័ន្តសាធារណៈមតិពិភពលោកអំពីការឈ្លានពានរបស់ទាហានសៀមលើដីខ្មែរតាមបណ្ដោយព្រំដែននោះ៕

**តមកពីទំព័រ១ គ**

ណែង ដ៏សក្តិសមកិត្តិយសមួយសំរាប់អាណត្តិទី៤ ។ ជាមួយគ្នានោះដែរ ព្រះអង្គក៏ត្រូវតែទទួលយកលក្ខខណ្ឌ របស់ប្រមុខរដ្ឋាភិបាល*ហ៊ុន សែន* និងក្រុមអ្នកចាស់ទុំ គណបក្សហ្វ៊ុនស៊ិនប៉ិចផងដែរ ។

សម្ដេចក្រុមព្រះ ដែលតាំងពីដើមទីមក បានប្រឆាំងរាល់ការបង្រួបបង្រួមណាមួយ ឱ្យទ្រង់ទៅធ្វើជាប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិចវិញ ដោយព្រះអង្គនិងមន្ត្រីឡេមឡឺម នៅជុំវិញព្រះអង្គមួយដំបរស្វា ចោទថាលោក*ញឹក ប៊ុនឆៃ* និងលោក*លឺ ឡាយស្រេង* បានធ្វើបក្សប្រហារ កាលពីថ្ងៃទី១៨ តុលា ២០០៦នោះ ។ ប៉ុន្តែស្ថានភាពសព្វថ្ងៃនេះ លោក*ហ៊ុន សែន* បានរុញព្រះអង្គ ឱ្យទ័លច្រកហើយ និងការបង្ខំឱ្យព្រះអង្គវិលមកដឹកនាំហ្វ៊ុនស៊ិនប៉ិចដែលជាស្នាព្រះហស្ថ របស់សម្ដេចឪព្រះ*នរោត្តម សីហនុ* វិញនោះ វាដូចលោក*ហ៊ុន សែន* បង្ខំព្រះអង្គ ឱ្យសោយព្រះកំហាកវិញដែរ ។ ដូច្នេះស្ថានភាពដ៏ស្មុគស្មាញនេះ ពិបាកនឹងធ្វើអោយព្រះអង្គសំរេចព្រះទ័យ ខ្លាំងណាស់ ។

សម្ដេចក្រុមព្រះ បានចេញសេចក្ដីថ្លែងការណ៍ដ៏ភ្ញាក់ផ្អើលមួយ ទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតដ៏អាក្រក់ បន្ទាប់ពីព្រះអង្គបានសន្ទនាគ្នាជាមួយលោក*ហ៊ុន សែន*តាមទូរស័ព្ទ, ហើយក្រោយមក សម្ដេចក្រុមព្រះ បានពន្យល់ប្រាប់ថ្នាក់ដឹកនាំ គណបក្សនរោត្តម រណប្ញទ្ធិ ថាលោក*ហ៊ុន សែន* យល់ព្រមលើកលែងទោស ថ្វាយព្រះអង្គ និងឱ្យព្រះអង្គ ធ្វើប្រធានព្រឹទ្ធសភាជំនួសលោក*ជា ស៊ីម* និងឱ្យលោក*ជា ស៊ីម* ធ្វើជាប្រធានរដ្ឋសភា និងលោក*ហេង សំរិន* ជាអនុប្រធានព្រឹទ្ធសភាវិញ ។

ប្រភពបានឱ្យដឹងថា ឥឡូវនាយករដ្ឋមន្ត្រី*ហ៊ុន សែន* បានដាក់លក្ខខណ្ឌ ឱ្យសម្ដេចក្រុមព្រះ វិលត្រឡប់មកធ្វើប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិចវិញ និងឱ្យតំណែង ជាទីប្រឹក្សារដ្ឋាភិបាល មានឋានៈស្មើនាយករដ្ឋមន្ត្រីគឺមិនបានធ្វើប្រជាប្រធានព្រឹទ្ធសភាទេ ។

ចំពោះបន្ទូល របស់ព្រះអង្គម្ចាស់*ស៊ីសុវត្ថិ ធម្មិកោ*ដែល ថាសម្ដេចក្រុមព្រះ ចង់ធ្វើជាប្រធាន ក្រុមប្រឹក្សារាជបល្ល័ង្កនោះគឺជាការមិនពិតទេ ព្រោះតំណែងនេះមិនអាចអោយព្រះអង្គ ធ្វើនយោបាយបានទៀតឡើយ ។

មន្ត្រីដែលស្និទ្ធ នឹងសម្ដេចក្រុមព្រះបាននិយាយថាលោក *ហ៊ុន សែន* នៅតែត្រូវការព្រះអង្គម្ចាស់ *រណប្ញទ្ធិ* ជានិច្ចទោះបីជាគណបក្សនរោត្តមរណប្ញទ្ធិទទួលបាន ២អាសនៈក៏ដោយ គឺដើម្បីមិនឱ្យរួបរួម ជាមួយគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស របស់លោក *កឹម សុខា* ។ មន្ត្រីដដែលបានឱ្យដឹងទៀតថាបើអាសនៈគណបក្សសម រង្ស៊ី, គណបក្សសិទ្ធិមនុស្ស និងគណបក្សនរោត្តមរណប្ញទ្ធិរួមគ្នា នឹងបាន៣១កៅអី ដែលជាចំនួនមួយ អាចធ្វើញត្តិបន្ទោសរដ្ឋាភិបាល បានគ្រប់ពេល ។ ការធ្វើញត្តិ នឹងបើកឱកាស អោយសមាជិកសភា នៅក្នុងក្រុមណាមួយនៃគណបក្សប្រជាជន បូកបញ្ចូលនឹងសម្លេង ៣១អាសនៈនោះ អាចរំលាយរដ្ឋាភិបាល ឬប្ដូរនាយករដ្ឋមន្ត្រីបានគ្រប់ពេល។

ប្រភពបានឱ្យដឹងថា ទ្រង់*រណប្ញទ្ធិ*បានយកហេតុផលនេះទៅតថ្លៃ ជាមួយលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ដើម្បីចង់បានតំណែងច្រើននៅក្នុងគណៈ

**តទៅទំព័រ៣ គ**

**តមកពីទំព័រ១ ស**

បន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី អាណត្តិទី៤របស់លោក*សុខ អាន* គ្រូធំរបស់លោក*ហ៊ុន សែន* ។ ប៉ុន្តែការព្យាយាមនេះ មិនបានជោគជ័យទេ ដោយលោក*ហ៊ុន សែន* រក្សាតំណែងលោក *សុខ អាន* ជារដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រីដដែល ។

ឧត្ដមសេនីយ៍ទោម្នាក់ នៃក្រសួងការពារជាតិ ដែលស្និទ្ធនឹងលោកស្រី*ម៉ែន សំអន* បានឱ្យដឹងថាលោកស្រី*ម៉ែន សំអន* ចង់បានតំណែង រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៃរដ្ឋាភិបាលអាណត្តិទី៤នេះ តែលោក*ហ៊ុន សែន* មិនព្រមទេ ដោយនិយាយថា លោក*សុខ អាន* បានចំណាយប្រាក់ អស់ជិត២លានដុល្លារកាលពីឃោសនាបោះឆ្នោត, ហើយលោកស្រី*ម៉ែន សំអន* ចំណាយអស់ប្រមាណតែ៩ម៉ឺនដុល្លារប៉ុណ្ណោះ។

ប្រភព បានអោយដឹងទៀតថា អ្នកចាស់ទុំគណបក្សប្រជាជនខ្មែរលោក*ជា ស៊ីម* ប្រធានគណបក្ស និងលោក*ហេង សំរិន* ប្រធានកិត្តិយសគណបក្សប្រជាជន ក៏បានគាំទ្រការទាមទាររបស់លោកស្រី*ម៉ែន សំអន* នេះដែរ ។ ប៉ុន្តែការគាំទ្រនោះ មិនបានធ្វើឱ្យមហិច្ឆតា លោកស្រី*ម៉ែន សំអន* ទទួលបានលទ្ធផលទេ ។

ឧត្ដមសេនីយ៍ដដែល បានឱ្យដឹងទៀតថា លោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* បានយល់ព្រមតម្លើង លោកស្រី*ម៉ែន សំអន* ជាឧបនាយករដ្ឋមន្ត្រីត្រួតក្រសួងចំនួន៥គឺក្រសួងការងារ ក្រសួងកិច្ចការនារី, ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, ក្រសួងសង្គមកិច្ច និងក្រសួងសុខាភិបាល ។ ជាមួយគ្នានោះ លោកស្រី*ម៉ែន សំអន* ក៏បានស្នើលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ត្រួតក្រសួងចំនួន២ទៀត ដែលអាចរកប្រភពប្រាក់ចំណូលបានច្រើន តែលោក*ហ៊ុន សែន* មិនព្រម ។

មន្ត្រីគណបក្សប្រជាជនបាននិយាយថា បញ្ជីឈ្មោះសមាជិកគណៈរដ្ឋមន្ត្រីថ្មី បានធ្វើរួចរាល់ហើយ គឺខុសពីបញ្ជីសមាជិកគណៈរដ្ឋមន្ត្រី មិនផ្លូវការផ្សាយជាសាធារណៈ កាលពីថ្ងៃទី២៧ ខែកក្កដា ២០០៨ ។ ប្រភពបានបន្តថា បញ្ជីឈ្មោះសមាជិក គណៈរដ្ឋមន្ត្រីថ្មីនេះមានការប្រែប្រួលខ្លះ ប៉ុន្តែមិនមានច្រើននោះទេ ។ ការប្រែប្រួលខ្លះវិញនេះ បន្ទាប់ពីក្រុមលោក*ជា ស៊ីម* និងលោក*ហេង សំរិន* ប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* តែងតាំងមនុស្សថ្មី ឱ្យកាន់តំណែងខ្ពស់ជាង សមាជិកគណបក្សប្រជាជន ដែលបានតស៊ូជាមួយបក្សជាយូរឆ្នាំមកហើយនោះ ។

មន្ត្រីគណបក្សប្រជាជនបានអោយដឹងថា រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភានិងព្រឹទ្ធសភារបស់លោកស្រី*ម៉ែនសំអន*សព្វថ្ងៃនេះ នឹងបានទៅលោកស្រី*សោម គឹមសួគ៌* ។

ឧត្ដមសេនីយ៍ ក្រសួងការជាតិ ដែលស្និទ្ធនឹងលោកស្រី*ម៉ែន សំអន* ដដែលបានអោយដឹងទៀតថា ភាពតានតឹងនៅក្នុងគណបក្សប្រជាជន ដែលឈានទៅដល់ ឱ្យមានការបោះឆ្នោតកញ្ចប់ ក្នុងការបង្កើតរដ្ឋសភា និងរដ្ឋាភិបាលថ្មីនេះ គឺផ្ដើមចេញពីការតែងតាំងសមាជិកគណៈរដ្ឋមន្ត្រីថ្មី ជាពិសេសលោក*ហ៊ុន សែន*កាងតែងតាំងមនុស្សរបស់គាត់ច្រើនពេក ។ ភាពតានតឹងនោះ មិនមានតែនៅក្នុងជួរ សមាជិកគណៈរដ្ឋមន្ត្រីនោះទេគឺមានទាំងតំណែងអភិបាល អភិបាលរង ខេត្តក្រុងទូទាំងប្រទេសផងដែរ ។

សេចក្ដីរាយការណ៍ បានឱ្យដឹងទៀតថារដ្ឋាភិបាលអាណត្តិទី៤នេះ នឹងមានបន្ថែម អភិបាលរងខេត្ត ក្រុង រដ្ឋលេខា និងអនុរដ្ឋលេខាធិការ នៅគ្រប់ក្រសួងទាំងអស់ ព្រមទាំងតំណែង នៅតាមនាយកដ្ឋានផងដែរ ។

ភាពតានតឹង នៅក្នុងគណបក្សប្រជាជនសព្វថ្ងៃនេះ គឺជាការរៀបចំសមាសភាព គណៈរដ្ឋមន្ត្រីថ្មី ដែលក្រុមលោក*ជា ស៊ីម*, លោក*ហេង សំរិន* ចង់ឱ្យមានតុល្យភាព ជាមួយនឹងក្រុមលោក*ហ៊ុន សែន*ដែលក្នុងនោះរួមទាំងកងកម្លាំងប្រដាប់អាវុធផងដែរ ។ ប៉ុន្តែលោក*ហ៊ុន សែន*ដែលមានចរិតកោងកាច និងមើលងាយ ប្រមាថចាស់ទុំ ដូចជាលោក*ជា ស៊ីម* នោះបានអាងយ៉ាងបញ្ចូលបក្ខពួកខ្លួន នៅក្នុងសមាជិកគណៈរដ្ឋមន្ត្រីថ្មី ដែលធ្វើឱ្យក្រុមខាងលោក*ជា ស៊ីម* និងលោក*ហេង សំរិន* មិនសប្បាយចិត្ត ។ ប៉ុន្តែការមិនសប្បាយចិត្តនេះ បានត្រឹមតែដេកឱបទុក ក្នុងដើមទ្រូងប៉ុណ្ណោះគ្មានហ៊ាននិយាយតតាំងជាចំហ ជាមួយលោក*ហ៊ុន សែន* នោះទេ ។

មន្ត្រីគណបក្សប្រជាជនបានបន្តទៀតថា កម្លាំងផ្ទៃក្នុងរួមគ្នា របស់លោក*ជា ស៊ីម* និងលោក*ហេង សំរិន* មិនស្មើគ្នានឹងកម្លាំងលោក*ហ៊ុន សែន* ទេ គឺទាំងតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិកគណៈរដ្ឋមន្ត្រី កងកម្លាំងប្រដាប់អាវុធ និងពិសេសនោះ គឺកម្លាំងនៅតាមខេត្ត-ក្រុងដូចជាអភិបាល អភិបាលរង ស្នងការ និងស្នងការរងខេត្ត-ក្រុងជាដើម ។

អ្នកវិភាគនិយាយថាទំនាស់ផ្ទៃក្នុងរបស់គណបក្សប្រជាជន អាចនឹងជម្រុញអោយមានការធ្វើរដ្ឋប្រហារ ផ្ទៃក្នុងគណបក្សដូចកាលពីខែកក្កដា ឆ្នាំ១៩៩៤ មិនជោគជ័យទៀត ដែលកាលធ្វើរដ្ឋប្រហារលើកមុននោះដឹកនាំដោយលោក*ស៊ិន សុង*, *ស៊ិន សេន*និងព្រះអង្គម្ចាស់*នរោត្តម ចក្រពង្ស* ។

ទោះយ៉ាងណា លោក*ហ៊ុន សែន* ត្រូវបានគេដឹងថា មានកម្លាំងប្រៀបជាង ខ្សែលោក*ជា ស៊ីម* និងលោក*ហេង សំរិន* គឺទាំងកងទ័ព ទាំងកម្លាំងនៅសមាជិកគណៈរដ្ឋមន្ត្រី។ ដូច្នេះហើយ បានជាលោកស្រី*ម៉ែន សំអន* ចង់បានតំណែងរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការ គណៈរដ្ឋមន្ត្រីរបស់លោក*សុខ អាន* មានការគាំទ្រពីលោក*ជា ស៊ីម* និងលោក*ហេង សំរិន* ក៏ដោយ ក៏លោក *ហ៊ុន សែន* មិនយល់ព្រមដែរ ៕

**តមកពីទំព័រ១ ម**

សន្លឹកឆ្នោតបំប៉ោងតួលេខដើម្បីចំណេញខ្លួនឯងផង ក៏គណបក្ស *ហ៊ុន សែន* បានសន្លឹកឆ្នោតតែជាង៣លានសម្លេងនៃអ្នកដែលមានឈ្មោះបោះឆ្នោតប្រមាណ ៨លាន១សែន២មុឺនសម្លេងក្នុងទូទាំងប្រទេស ។ នេះបញ្ជាក់ឱ្យគណបក្សប្រជាជន *ហ៊ុន សែន* ដឹងថា ឆន្ទៈទឹកចិត្តប្រជារាស្ត្រខ្មែរយ៉ាងណា ។ ពោលគឺប្រជារាស្ត្រខ្មែរម្ចាស់សន្លឹកឆ្នោតចង់បានការផ្លាស់ប្តូរ សំដៅដល់ការដកគណបក្សប្រជាជន*ហ៊ុនសែន*ឱ្យចេញពីការត្រួតត្រាដែលបង្កើតឱ្យមានការក្តៅក្រហាយពាសពេញប្រទេសនោះ ។

ការបោះឆ្នោតកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ កន្លងទៅថ្មីៗនេះ បើទោះបីជាគណៈកម្មាធិការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់បានជួយដុតដៃដុតជើងក្នុងល្បែងអនុវត្តផែនការគណបក្សប្រជាជនឱ្យលួចបន្លំសន្លឹកឆ្នោត និងបំភិតបំភ័យប្រជារាស្ត្រយ៉ាងណា ក៏គណបក្សនេះបានសម្លេងត្រឹមតែ៣លាន៤សែនប៉ុណ្ណោះ ។ហើយក្នុងចំនួននេះទៀតសោតក៏មានយួនយ៉ាងសន្ធឹកសន្ធាប់ចូលជួយបោះឆ្នោតឱ្យគណបក្សប្រជាជន *ហ៊ុន សែន* ផងដែរ ។

គេអាចដឹងបានថា បើទោះបីជាគណបក្សប្រជាជន *ហ៊ុន សែន*មានបណ្តាញគ្រប់ទីកន្លែងដល់ថ្នាក់ក្រុមតាមឃ្លាំមើលប្រជារាស្ត្រ បំភិតបំភ័យប្រជារាស្ត្រ និងអនុវត្តវិធីសព្វបែបយ៉ាង រួច គ.ជ.ប បិទភ្នែកបើកដៃឱ្យអាជ្ញាធររៀបចំឯកសារទម្រង់១០១៨ដាក់មនុស្សអត់មានលក្ខណៈសម្បត្តិបោះឆ្នោតឱ្យបោះឆ្នោតបង្កើនសម្លេងគណបក្សប្រជាជនក្នុងពេលដែលគេលុបបំបាត់ម្ចាស់សម្លេងឆ្នោតជាង១លាននាក់នោះក៏ដោយ ក៏គណបក្សប្រជាជន*ហ៊ុន សែន* បានសម្លេងក្នុងខ្ទង់៣លាន៤សែននាក់ប៉ុណ្ណោះ តួលេខនេះបើគិតជាភាគរយវិញ ក្នុងចំនួនអ្នកដែលបានទៅបោះឆ្នោតជាង ៦លាន ក៏ឃើញថាបានតែ៥៦ ភាគរយប៉ុណ្ណឹង ។

ហើយបើគេគិតឱ្យដល់ថាតួលេខនេះប្រៀបធៀបនឹងចំនួនអ្នកដែលមានលក្ខណៈសម្បត្តិបោះឆ្នោតជាង៨លាន១សែន ២មុឺននាក់ក្នុងទូទាំងប្រទេសនោះក៏គេដឹងថាគណបក្សប្រជាជនមានសម្លេងគាំទ្រប្រមាណតែ៤០ភាគរយដដែលដូចកាលពីឆ្នាំ១៩៩៣ ។

គេអាចសួរថា តើហេតុអ្វីបានជានៅក្នុងអំណាចអួតក្អេងក្អាងរបស់ *ហ៊ុន សែន* ជាង២០ ឆ្នាំមកនេះ គណបក្សប្រជាជនមានបណ្តាញគ្រប់ទិសទី និងមានប្រព័ន្ធផ្សព្វផ្សាយ រួមទាំងកេងយករបស់រដ្ឋបំរើការឃោសនាឱ្យគណបក្សនេះ ម្តេចក៏គណបក្សប្រជាជនបានសម្លេងមិនដល់ពាក់កណ្តាលដូច្នេះ ?

ទាំងអស់ហ្នឹងមកអំពីទឹកចិត្តប្រជារាស្ត្រខ្មែរយល់ច្បាស់ថាលុះត្រាតែមានការផ្លាស់ប្តូរទើបខ្មែរអាចរៀបចំប្រទេសឱ្យត្រឹមត្រូវឡើងវិញ លែងឱ្យមានការជិះជាន់ សង្កត់សង្កិនធ្វើប្រាប់ប្រជារាស្ត្រ ក៏ដូចជាបញ្ឈប់ឱ្យខាងតែបាននូវការបំផ្លិចបំផ្លាញធនធានរបស់ប្រទេស ក៏ដូចជាការហូរចូលនៃជនអន្តោប្រវេសន៍យួនខុសច្បាប់នោះ ។

បែបនេះហើយបានជា *ហ៊ុន សែន*ចេះតែមានហេតុផលគ្រប់បែបយ៉ាងនិងប្រឹងអនុវត្តនយោបាយបំបែកបំបាក់គណបក្សនានាទាំងតាមព្យាបាទគណបក្សសមរង្ស៊ីយ៉ាងណាក៏គណបក្សសមរង្ស៊ីនៅតែបានកំណើនសម្លេងគាំទ្ររបស់ប្រជារាស្ត្រច្រើនឡើង ដែលរឹតតែធ្វើឱ្យ *ហ៊ុន សែន* មានការខ្វល់ខ្វាយភ័យព្រួយសម្រាប់អនាគតដែលមិនមានវិធានការអនុវត្តតាមផ្លូវទុច្ចរិតនានាជាការលួចបន្លំសន្លឹកឆ្នោតនិងការបំភិតបំភ័យប្រជារាស្ត្រគ្រប់ទិសទីទេនោះ ។

តាមមតិរបស់អ្នកសង្កេតការណ៍ដែលមើលឃើញថាការបោះឆ្នោតកន្លងទៅពោរពេញដោយភាពអយុត្តិធម៌មិនគួរឱ្យទទួលយក ទាំងលទ្ធផលមិនឆ្លុះបញ្ចាំងនូវឆន្ទៈពិតប្រាកដរបស់ប្រជារាស្ត្រខ្មែរគ្រប់ទីកន្លែងនោះ គណបក្សប្រជាជន *ហ៊ុន សែន* មានសម្លេងគាំទ្រពិតប្រាកដតែជាង២លាននាក់ប៉ុណ្ណោះ ។ ហើយអ្នកដែលដឹងកម្លាំងរបស់គណបក្សប្រជាជន គឺមានតែគណបក្សប្រជាជនខ្លួនឯង ដូចដែលគណបក្សនេះបានដាក់ផែនការគាបសង្កត់មន្ត្រីតាមលំដាប់លំដោយរហូតដល់មូលដ្ឋានជាមួយការព្រមានថា បើមណ្ឌលភូមិឃុំណាគណបក្សប្រជាជនចាញ់ឆ្នោត និងមានការដកងារតំណែងមន្ត្រីអស់នេះតាមលំដាប់នោះ ដូច្នេះក៏មានគម្រោង និងអនុវត្តផែនការខូចទុច្ចរិត លួចបន្លំសន្លឹកឆ្នោតបំភិតបំភ័យប្រជារាស្ត្រជាពិសេសការប្រើទម្រង់ ១០១៨ដើម្បីប្លន់សន្លឹកឆ្នោតទៅឱ្យគណបក្សប្រជាជននោះ ។

គណបក្សប្រជាជនបានកៅអីសភាជាបណ្តោះអាសន្នប្រមាណ ៩០នោះ មិនមែនមានន័យថាគណបក្សនេះបានសម្លេងគាំទ្រពីប្រជារាស្ត្រច្រើនលើសលប់នោះទេ ។ ផ្ទុយទៅវិញគឺមកពីគណបក្សនេះចេះប្រើ គ.ជ.ប ជាឧបករណ៍របស់ខ្លួនអនុវត្តគ្រប់ល្បិចកលដើម្បីផ្តល់ប្រៀបឱ្យមនុស្សគណបក្សប្រជាជនលួចបន្លំសន្លឹកឆ្នោតបង្កើនចំនួនសន្លឹកឆ្នោតក៏ដូចជាបំភិតបំភ័យប្រជារាស្ត្រដែលមិនគាំទ្រគណបក្សខ្លួនដើម្បីឱ្យគណបក្សប្រជាជនឃើញមានសម្លេងភាគរយខ្ពស់ជាងគេ ។ ហើយបើរួមផ្សំនឹងការប្រើរូបមន្តបែងចែកអាសនៈសភាឆ្នាំ១៩៩៨ដែលមិនមានលក្ខណៈយុត្តិធម៌នោះ ដូច្នេះរូបមន្ត និងវិធីអស់ទាំងនេះបានជួយឱ្យគណបក្សប្រជាជន *ហ៊ុន សែន* ប្លន់យកអាសនៈសភាពីគណបក្សនានាដល់ខ្ទង់ប្រមាណជាង៣០អាសនៈឯណោះ ៕

**តមកពីទំព័រ២ គ**

រដ្ឋមន្ត្រី រហូតធ្វើឱ្យលោក*ហ៊ុន សែន* ខឹង និងឈប់ទទួលទូរស័ព្ទព្រះអង្គមួយរយៈសិន ។ ប៉ុន្តែលោក*ហ៊ុន សែន* អាចនឹងធ្វើសម្បទាន អោយសម្តេចក្រុមព្រះ ជាច្រើនថែមទៀត បើព្រះអង្គ យល់ព្រមកធ្វើជាប្រធាន គណបក្សហ៊្វុនស៊ិនប៉ិចវិញនោះ ។

អ្នកដែលស្និទ្ធ នឹងសម្តេចក្រុមព្រះបានអោយដឹងថា ព្រះអង្គម្ចាស់*រណឫទ្ធិ* បានបង្ហាញព្រះទ័យ ចង់វិលត្រឡប់ទៅធ្វើជាប្រធានហ៊្វុនស៊ិនប៉ិចវិញ តែនៅត្រង់ថា អ្នកចាស់ទុំនៃគណបក្សហ៊្វុនស៊ិនប៉ិចមិនទទួលអ្នកដែលស្និទ្ធ នឹងសម្តេចក្រុមព្រះចំនួន៥នាក់ គឺលោក*សៅ រ៉ានី*, លោក*យូ ហុកគ្រី*, លោក*មុត ចន្ថា*, លោក*អាណន់ ដាយ៉ាត* និងលោក*ថាវ គីមហោ* ។ ក្នុងចំណោមមនុស្សទាំង៥នាក់នេះ គឺមានបីនាក់ ដែលលោក*ហ៊ុន សែន* មិនចង់ឱ្យនៅក្បែរព្រះអង្គម្ចាស់*រណឫទ្ធិ* ដែរ គឺលោក*មុត ចន្ថា*, លោក*អាណន់ ដាយ៉ាត* និងលោក*ថាវ គីមហោ* ដែលបានរិះគន់ លោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ធ្ងន់ៗ នាពេលកន្លងមក ។

មន្ត្រី គណបក្សហ៊្វុនស៊ិនប៉ិចបានដាក់លក្ខខណ្ឌ ឱ្យសម្តេចក្រុមព្រះ ផ្ទេរឈ្មោះដីទីស្នាក់ការគណបក្សហ៊្វុនស៊ិនប៉ិច ១១ ហិកតា នៅជាយក្រុងភ្នំពេញ តម្លៃ ជាង១០លានដុល្លារឱ្យគណបក្សហ៊្វុនស៊ិនប៉ិចវិញទើបគណបក្សហ៊្វុនស៊ិនប៉ិច ទទួលយកព្រះអង្គ ឱ្យធ្វើជាប្រធានគណបក្ស ។

ទោះយ៉ាងណា សម្តេចក្រុមព្រះកំពុងស្ថិតនៅក្នុងស្ថានភាពទ័លច្រក យ៉ាងច្បាស់ក្រឡែតទៅហើយ ព្រោះតម្លៃរបស់ព្រះអង្គដែលគេមើលឃើញថាសំខាន់នោះ គឺការមិនប្រឆាំងនឹងលទ្ធផលបោះឆ្នោត ដែលកាដូនេះព្រះអង្គបានជូនលោក*ហ៊ុន សែន* រួចហើយ តែលោក*ហ៊ុន សែន* មិនទាន់បានផ្តល់ជូនព្រះអង្គវិញទេ គឺមិនទាន់ស្នើទៅព្រះមហាក្សត្រព្រះបរមនាថ *នរោត្តម សីហមុនី* ប្រទានការលើកលែងទោសថ្វាយព្រះអង្គឡើយ ។ បញ្ហានេះវាដូចលោក*ហ៊ុន សែន* រុញព្រះអង្គឱ្យទ័លច្រក ហើយបង្ខំឱ្យសោយ ព្រះកំហាកខ្លួនឯងវិញយ៉ាងដូច្នេះដែរ ។បញ្ហានេះគេមើលឃើញថា សម្តេចក្រុមព្រះ ដូចជាធ្វើឱ្យត្រីក៏បាត់បង់ហើយផង់ក៏ដាចទៀត ៕

**តមកពីទំព័រ១ ៩**

បណ្តាលឱ្យមានការ ជួបចរចាគ្នាថ្នាក់មេទ័ពកំពូល និងថ្នាក់រដ្ឋក្រសួងការបរទេសនិងថ្នាក់មេទ័ពភូមិភាគ សរុបចំនួន៦លើក ។

នៅមុនការចរចាមួយថ្ងៃ ឬនៅក្រោយការចរចា ប៉ុន្មានថ្ងៃ ចោរឈ្លានមពានសៀម បានបន្តរំកិលចូលក្នុងដីខ្មែរ ជាបន្តបន្ទាប់ ដូចជាមុនចរចា នៅខេត្តសៀមរាបកាលពីថ្ងៃទី២៨ កក្កដា ទាហានសៀមបានចូលកាន់កាប់ប្រាសាទតាមាន់ធំខ្មែរ និងនៅមុនចរចានៅទីក្រុងហួរហ៊ីនប្រទេសសៀមពួកទាហានសៀមបោះត្រា លើប្រជាពលរដ្ឋខ្មែរ ដែលចូលទស្សនាប្រាសាទតាមាន់ធំ ។ មុនគំរោងនៃការចរចា នៅថ្ងៃទី២៩ ខែសីហា ២០០៨ ទាហានសៀមបានបោក GPS របស់មន្ត្រីក្រសួងវប្បធម៌ខ្មែរ និងស្នើអោយប្រជាពលរដ្ឋខ្មែរ ជាង១០០គ្រួសារនៅជប់គគីរ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យចេញពីលំនៅឋានរបស់ខ្លួន ។

ដោយសារតែ ភាពអត់ធ្មត់របស់ខ្មែរ និងភាពកំសាករបស់លោក*ហ៊ុន សែន* នេះហើយ បានធ្វើឱ្យចោរសៀមបន្តឈ្លានពានចូលដីខ្មែរ ប្រាសាទខ្មែរជាច្រើនកន្លែងទៀត ។ ការឈរឱបដៃមើលចោរសៀម ឈ្លានពានខ្មែរនេះហើយធ្វើអោយទូរទស្សន៍សៀម បានសរសើរប្រមុខរដ្ឋាភិបាលខ្មែរ លោក*ហ៊ុន សែន* ថាជាវីរបុរសសតវត្សរ៍ទី២១ ។

ទស្សនាវដ្តី ក្នុងស្រុកមួយបានផ្សាយ ដោយដកស្រង់ខ្លឹមសារ នៃការធ្វើអត្ថាធិប្បាយរបស់ទូរទស្សន៍ ប៉ុស្តិ៍លេខ៣ សៀមថាលោក*ហ៊ុន សែន* បានតាំងចិត្តធ្វើនយោបាយ ដោយត្រជាក់រហូតកម្មវិធី ទូរទស្សន៍ប៉ុស្តិ៍លេខ៣របស់សៀម បានផ្សាយ និងធ្វើអត្ថាធិប្បាយសរសើរប្រមុខរដ្ឋាភិបាលខ្មែរ ។

ក្រោយពីការសរសើរលោក*ហ៊ុន សែន* របស់ស្ថានីយ៍ទូរទស្សន៍សៀមនេះប៉ុន្មានថ្ងៃ គឺមានសេចក្តីរាយការណ៍ថា ប្រទេសកម្ពុជា បានយកប្រាសាទព្រះវិហាររបស់ខ្មែរដាក់ហ៊ុនជាមួយចោរសៀមលើវិស័យទេសចរ ។ ការសំរេចរបស់រដ្ឋាភិបាលខ្មែរនេះបានធ្វើឱ្យមានការរិះគន់យ៉ាងខ្លាំង ពីអ្នកស្នេហាជាតិខ្មែរ, ហើយថាការសំរេចដាក់ផលប្រយោជន៍រួមជាមួយសៀម លើវិស័យទេសចរនៅប្រាសាទព្រះវិហារនេះគឺជាការទន់ជ្រាយហួសហេតុ របស់មេដឹកនាំខ្មែរ ។

អ្នកច្បាប់ជាន់ខ្ពស់ របស់ប្រទេសកម្ពុជាម្នាក់ បាននិយាយថា ប្រាសាទព្រះវិហារ គឺជាទ្រព្យសម្បត្តិមហាសាល របស់ខ្មែរ ដែលតុលាការអន្តរជាតិនៅទីក្រុងឡាអេ កាត់ក្តីអោយខ្មែរឈ្នះ កាលពីថ្ងៃទី១៥ ខែមិថុនា១៩៦២ ។ដូច្នេះ ប្រាសាទព្រះវិហារគឺជាកម្មសិទ្ធិផ្តាច់មុខរបស់ខ្មែរដែលពិភពលោកបានដឹងឮទៀតផង ។ ចុះហេតុអ្វីបានជារដ្ឋាភិបាលកញ្ចប់ លោក*ហ៊ុន សែន* យកសម្បត្តិរបស់ជាតិឯង ទៅដាក់ហ៊ុនជាមួយនឹងប្រទេសសៀមដែលជាចោរឈ្លានពានខ្មែរវិញ ។អ្នកច្បាប់ដដែលបានបន្តទៀតថា លោក*ហ៊ុន សែន* ធ្វើបែបនេះ វាដូចជាចាត់ទុក ប្រជាពលរដ្ឋខ្មែរជាទីងមោង, ហើយបង្ហាញថាប្រទេសកម្ពុជា ក្រោមការដឹកនាំរបស់គណបក្សប្រជាជន គ្មានសមត្ថភាព ក្នុងការអភិវឌ្ឍន៍លើវិស័យទេសចរណ៍ នៅប្រាសាទព្រះវិហារនោះទេ ។

ក្រុមអ្នកច្បាប់ខ្មែរ បានអះអាងថាគ្រាន់តែករណីប្រាសាទព្រះវិហាររបស់ខ្មែរមួយ ចោរសៀម មានអ្នកចេះដឹងផ្នែកច្បាប់ជាន់ខ្ពស់រាប់សិបនាក់ កំរិតស្តង់ដារអន្តរជាតិ ធ្វើការជាមួយកម្ពុជា ។ ឯភាគីកម្ពុជាវិញ មានតែអ្នកនិយាយអួតអំពីលោក*ហ៊ុន សែន* ដើម្បីការពារបុណ្យសក្តិ គឺមិនហ៊ាននាំគ្នានិយាយការពិតផ្តល់ជាគំនិតឱ្យលោក*ហ៊ុន សែន* ធ្វើយ៉ាងណា ដើម្បីបណ្តេញចោរសៀមពីដីខ្មែរឡើយ ។

ក្រុមអ្នកច្បាប់ដដែល បានបន្តទៀតថា ខ្មែរសំបូរធនធានមនុស្សណាស់ ដែលកំរិតស្តង់ដារអន្តរជាតិ, ប៉ុន្តែពួកគេមិនលក់ឧត្តមគតិ ឱ្យលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ដែលធ្វើឱ្យលោក*ហ៊ុន សែន* មិនអោយគេធ្វើកិច្ចការនេះ ។ តែបើអ្នកចេះតែនិយាយបញ្ជោរ លោក*ហ៊ុន សែន* ដូចជាលោក *ផៃ ស៊ីផាន* អ្នកនាំពាក្យ គណៈរដ្ឋមន្ត្រីនោះ គឺលោក*ហ៊ុន សែន* ចូលចិត្តណាស់ ។ ពួកនេះ បើទោះបីជាការចរចា ទទួលបរាជ័យ គ្មានបានផលអ្វីសោះ ក៏គេនិយាយថាជោគជ័យដែរ គឺជោគជ័យនោះ ជាការបើកដៃឱ្យចោរសៀម បន្តឈ្លានពានចូលដីខ្មែរច្រើនកន្លែងទៀត ឬយ៉ាងណា ?

ក្រុមអ្នកច្បាប់ បាននិយាយថា សៀមដែលលោភលន់ ចង់បានប្រយោជន៍ពីខ្មែរ ដោយគ្មានការអៀនខ្មាសនេះនៅក្នុងពេលប្រទេសរបស់គេ កំពុងតែជួបនូវភាពវឹកវរ ។ ចុះបើសិនប្រទេសសៀម មានស្ថេរភាពនោះ តើចោរសៀមឈ្លានពានទឹកដីខ្មែរ ដល់កំរិតណាទៅ ។ ដូច្នេះហើយបានជាទូរទស្សន៍សៀមលើកតម្កើងលោក*ហ៊ុន សែន* ថាគឺជាវីរបុរសសតវត្សរ៍ទី២១ ដោយសារតែចោរសៀមឈ្លានពានខ្មែរជាច្រើនកន្លែងទៀតក៏លោក*ហ៊ុន សែន* នៅស្ងៀម, តែបើខ្មែរគ្នាឯងវិញ ចាំមើលលោក*ហ៊ុន សែន* ធ្វើឱ្យមើល, ហើយមានពេលខ្លះ លោក*ហ៊ុន សែន* ប្រើពាក្យអាមឹងប្រមាថមនុស្សចាស់ទៀតផង ៕

**តមកពីទំព័រ៤ ឃ**

ប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម និងជាអតីតសមាជិកព្រឹទ្ធសភាមកពីគណបក្សសមរង្ស៊ីបានសំណូមពរដល់ព្រះមហាក្សត្រចំនួន៥ចំណុចដើម្បីឱ្យព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងយកទៅពិភាក្សាជាមួយមេដឹកនាំយួន ។

សំណូមពររបស់លោក*ថាច់ សេដ្ឋា* ដែលបានដាក់ថ្វាយព្រះមហាក្សត្រខ្មែរនាពេលនោះរួមមាន :

១-សូមអាជ្ញាធរវៀតណាមដោះលែងព្រះសង្ឃ៥ព្រះអង្គដែលបានផ្សឹក និងកាត់ទោសដាក់ពន្ធនាគារពី២ឆ្នាំ ទៅ៤ឆ្នាំ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧ដោយសារតែការតវ៉ាក្នុងការសិក្សារៀនសូត្រអក្សរសាស្ត្រខ្មែរ និងប្រឆាំងនឹងបំរាមមិនឱ្យព្រះសង្ឃចេញទ្រង់បិណ្ឌបាត្រ ។

ព្រះសង្ឃទាំង៥អង្គនោះមាន ១.ព្រះភិក្ខុ *គីម មឿន* ជាប់ពន្ធនាគារ៤ឆ្នាំ ។២.ព្រះភិក្ខុ *យាញ តូ* ជាប់ពន្ធនាគារ៤ឆ្នាំ ។ ៣.ព្រះភិក្ខុ *លី ធឿន* ជាប់ពន្ធនាគារ២ឆ្នាំ ។៤.ព្រះភិក្ខុ *ថាច់ ធឿង* ជាប់ពន្ធនាគារ២ឆ្នាំ ។ ៥.ព្រះភិក្ខុ *លី វ៉ាង* ជាប់ពន្ធនាគារ២ឆ្នាំ ។

២-សូមអាជ្ញាធរវៀតណាមដោះលែងព្រះតេជគុណ*ទឹមសាខន* ព្រះចៅអធិការវត្តភ្នំដិនខាងជើង ឃុំភ្នំដិន ស្រុកគិរីវង្ស ខេត្តតាកែវ ដែលត្រូវសម្តេចសង្ឃរាជ *ទេព វង្ស* ចាប់ផ្សឹកដោយរំលោភព្រះវិន័យសង្ឃទាំងកំរោល រួចបញ្ជូនទៅកាត់ទោសនៅប្រទេសវៀតណាម ទាំងរំលោភរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ព្រះតេជគុណ *ទឹម សាខន* ត្រូវតុលាការវៀតណាមកាត់ទោសឱ្យជាប់ពន្ធនាគារចំនួន៦ឆ្នាំ ប៉ុន្តែឮរចំនួន៥ឆ្នាំ ។ បើគិតពីថ្ងៃចាប់ខ្លួនរហូតបច្ចុប្បន្ន ព្រះអង្គបានស្ថិតនៅក្នុងពន្ធនាគារជិតមួយឆ្នាំហើយ ។

៣-អនុញ្ញាតប្រជារាស្ត្រខ្មែរនៅប្រទេសវៀតណាម( កម្ពុជាក្រោម) គោរពទំនៀមទម្លាប់របស់ខ្លួនដោយសេរី ។ដូចជាបុណ្យកឋិនទាន តាមពុទ្ធានុញ្ញាតក្នុងមួយឆ្នាំពុទ្ធសាសនិកជនអាចធ្វើបានពេញមួយខែតែនៅខេត្តឃ្លាំង ពលលាវទឹកខ្មៅ អាជ្ញាធរវៀតណាមអនុញ្ញាតឱ្យធ្វើតែមួយថ្ងៃប៉ុណ្ណោះ ។

៤-ដើម្បីបង្ហាញពីទំនាក់ទំនងជាមិត្តភាពកាន់តែល្អប្រសើររវាងកម្ពុជា-វៀតណាមថែមទៀត នោះសូមភាគីវៀតណាមអនុញ្ញាតបើកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតរងនៅខេត្តឃ្លាំងឡើងវិញ ព្រោះវិទ្យាស្ថាននេះមានការចូលរួមចំណែកកសាងពីព្រះករុណាព្រះបាទសម្តេចព្រះ *នរោត្តម សីហនុ* ព្រះមហាវីរក្សត្រនៅក្នុងទស្សវត្សឆ្នាំ៤០ផងដែរ ។

៥-ស្នើរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមដែលរៀបចំកម្មវិធីបំពេញរាជទស្សនកិច្ចថ្វាយព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងនេះ សូមមេត្តារៀបចំថ្វាយព្រះអង្គបានយាងទៅកាន់តំបន់ដែលមានប្រជារាស្ត្រខ្មែររស់នៅច្រើន ដើម្បីប្រជារាស្ត្រ និងព្រះសង្ឃខ្មែរទាំងនោះបានក្រាបបង្គំគាល់ព្រះអង្គដោយផ្ទាល់ ។

ឥឡូវនេះល្បីថាអាជ្ញាធរយួនបានដោះលែងព្រះតេជគុណ *ទឹម សាខន* ហើយ តែមិនអនុញ្ញាតឱ្យព្រះអង្គបាននិមន្តមកកាន់ប្រទេសកម្ពុជាវិញឡើយ និងត្រូវសមត្ថកិច្ចយួនតាមដានគ្រប់ពេលវេលាទៀត តើរដ្ឋាភិបាលខ្មែរសព្វថ្ងៃត្រូវដោះស្រាយដោយរបៀបណា ? ឬមួយរដ្ឋាភិបាលខ្មែរដែលដឹកនាំដោយលោក *ហ៊ុន សែន* មិនឈឺឆ្អាលនឹងសាច់ឈាមខ្មែរដែលត្រូវអាជ្ញាធរយួនជិះជាន់សង្កត់សង្កិនទេ ?

ចាំមើលស្ថានទូតយួនប្រចាំក្រុងភ្នំពេញត្រូវឆ្លើយតបយ៉ាងដូចម្តេចដើម្បីឱ្យស័ក្តិសមទៅនឹងអ្វីដែលខ្លួនបានប្រព្រឹត្តចំពោះអតីតព្រះសង្ឃ *ទឹម សាខន* នោះ ៕

**សេវាទទួលទិញសម្ភារៈចាស់ៗ**

មានទទួលទិញ : ផ្ទះឈើ ផ្ទះថ្ម និងសំណង់អគារចាស់ៗតូច-ធំ គ្រប់ប្រភេទដែលត្រូវការរុះរើ ឬវាយចោល និង សម្ភារៈអេតចាយជាច្រើនមុខទៀតដូចជា : ដែក ស្ពាន់ អាលុយមីញ៉ូម ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង អាគុយ ម៉ូទ័រ ។ល។

-មានសេវាចុះទិញតាមខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា

-មានទទួលទិញក្នុងតម្លៃសមរម្យ

-ចំពោះអ្នកដែលផ្តល់ព័ត៌មានក្នុងការទិញលក់នេះ ក្រុមហ៊ុននឹងផ្តល់កម្រៃជើងសារបន្ថែម

ទំនាក់ទំនងទូរស័ព្ទលេខ : **017 606 125**

**ក្រុមហ៊ុនភាពយន្ត ជនបទ**

**មានទទួលបញ្ចាំង ខ្សែភាពយន្តខ្នាតធំ ក្នុងពិធីផ្សេងៗ មានពន្លឺច្បាស់ ទំនាក់ទំនងតាមទូរស័ព្ទ**

**012 66 44 67**

**015 66 44 67**

ខ្មែរម្ចាស់ស្រុក

Khmer Machas Srok News

ការិយាល័យនិពន្ធ

Tel : 012 969 832 , 012 850 690

Fax : 023 987 411

E-mail: kmsnews@gmail.com

www.kmsblog.wordpress.com

ផ្នែកផ្សាយពាណិជ្ជកម្ម

Tel: 012 850 690 , 017 360 678,

015 645 170

**សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០៤**
Tel: 012 850 690 / 017 360 678 , Fax: 023 987 411

**តមកពីទំព័រ១ ម**

បានដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញផងដែរនោះ ក៏ត្រូវក្រុមប្រឹក្សាដ៏កំពូលមួយនេះបដិសេធនិងបិទផ្លូវតវ៉ាដូចគណបក្សសមរង្ស៊ីដែរ ។

ដោយសារតែក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសបិទផ្លូវតវ៉ាហើយនោះ ទើបគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានធ្វើជាលិខិតទៅក្រុមមេដឹកនាំប្រទេសចំនួន១៨នៅលើពិភពលោកដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ដែលបានត្រួសត្រាយផ្លូវសម្រាប់ដំណើរការប្រជាធិបតេយ្យសេរីពហុបក្សជាលើកដំបូងនៅក្នុងប្រទេសកម្ពុជាតាមរយៈនៃការបោះឆ្នោតដើម្បីឱ្យជួយដោះស្រាយចំពោះភាពមិនប្រក្រតីក្នុងការបោះឆ្នោតជ្រើសរើសអ្នកតំណាងរាស្ត្រអាណត្តិទី៤កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨កន្លងទៅ ។

លោក *សម រង្ស៊ី* ប្រធានគណបក្សសមរង្ស៊ី បានមានប្រសាសន៍ថា "*ប្រទេសជាហត្ថលេខីទាំងនោះត្រូវតែស្វែងរកដំណោះស្រាយចំពោះភាពមិនប្រក្រតីដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងការបោះឆ្នោតនេះ* " ។

មេដឹកនាំគណបក្សប្រឆាំងដ៏ល្បីឈ្មោះរូបនេះបានបញ្ជាក់យ៉ាងច្បាស់កាលពីថ្ងៃព្រហស្បតិ៍ថា "*គណបក្សប្រឆាំងបានសម្រេចសរសេរលិខិតទៅប្រទេសជាហត្ថលេខី នៃកិច្ចព្រមព្រៀងក្រុងប៉ារីសដើម្បីធ្វើឱ្យបណ្តាប្រទេសទាំងនោះនឹកឃើញឡើងវិញក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន* " ។

លោក *សម រង្ស៊ី* បានសង្កត់ធ្ងន់ថា "*យើងចង់ឱ្យបណ្តាប្រទេសជាហត្ថលេខីទាំងអស់នោះកុំទទួលស្គាល់ ឬក៏អបអរចំពោះលទ្ធផលនៃការបោះឆ្នោតដ៏អាក្រក់នេះឱ្យសោះ ។ ហើយត្រូវធ្វើយ៉ាងណាជួយស្វែងរកដំណោះស្រាយរាល់ភាពមិនប្រក្រតីនៅក្នុងការបោះឆ្នោតកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៨ផង* " ។

ជាងនេះទៀត លោក *សម រង្ស៊ី* ប្រធានគណបក្សសមរង្ស៊ី បានគូសបញ្ជាក់ថា "*បណ្តាប្រទេសទាំងនោះគួរតែរារាំងគណបក្សប្រជាជនកម្ពុជាកុំឱ្យធ្វើការគំរាមកំហែងដើម្បីបែងចែកអាសនៈសភារបស់គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សដោយវិធីទុច្ចរិតឱ្យសោះប្រសិនបើគណបក្សប្រឆាំងទាំងពីរធ្វើពហិការមិនចូលរួមសម័យប្រជុំសភាលើកដំបូងនោះ* " ។

លិខិតសារទុក្ខរបស់គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សដែលចុះហត្ថលេខាដោយលោក *សម រង្ស៊ី* និងលោក *កឹម សុខា* បានលាតត្រដាងពីបំណងរបស់គណបក្សប្រឆាំងទាំងពីរដើម្បីធ្វើឱ្យប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសចាប់អារម្មណ៍ទៅនឹងការអភិវឌ្ឍន៍នយោបាយមួយដែលកំពុងធ្វើដំណើរប្រាសចាកពីមាគ៌ារបស់ប្រជាធិបតេយ្យសេរីពហុបក្សឆ្ពោះទៅរកគ្រោះមហន្តរាយ និងផ្ទុយពីកិច្ចព្រមព្រៀងក្រុងប៉ារីសថែមទៀតផង ។

លោក *សម រង្ស៊ី* និងលោក *កឹម សុខា* បានដាក់ការចោទប្រកាន់គណបក្សប្រជាជនកម្ពុជាដែលជាគណបក្សកាន់អំណាច និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលលំអៀងទៅរកគណបក្សកាន់អំណាចពីបទលុបឈ្មោះអ្នកបោះឆ្នោតរាប់រយពាន់នាក់ដែលមាននិន្នាការគាំទ្រគណបក្សប្រឆាំងចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ។

មិនតែប៉ុណ្ណោះគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានធ្វើការឆ្លុះបញ្ចាំងឱ្យឃើញថា "*ការបន្លំនេះ ក៏ជាប់ពាក់ព័ន្ធនឹងការរក្សាទុកឈ្មោះខ្មោចរាប់រយនាក់ដើម្បីបង្កើនសន្លឹកឆ្នោតបំរុងក្លែងក្លាយសម្រាប់ផ្តល់ឱ្យគណបក្សប្រជាជនតាមរយៈនៃការចេញទម្រង់បែបបទលេខ ១០១៨ ឱ្យដល់ជនទាំងឡាយណាដែលពុំមានសិទ្ធិបោះឆ្នោត*" ។

ម្យ៉ាងទៀតបើយោងតាមការអត្ថាធិប្បាយរបស់លោក *សម រង្ស៊ី* និងលោក *កឹម សុខា* ត្រូវបានពួកលោកសង្កត់ធ្ងន់ថា "*ប្រភេទនៃការបោះឆ្នោតក្លែងក្លាយដូច្នេះគឺរំលោភយ៉ាងកម្រោលទៅនឹងកិច្ចព្រមព្រៀងក្រុងប៉ារីសដែលកន្លងមកបានសម្រេចឱ្យប្រទេសកម្ពុជាជ្រើសរើសអ្នកដឹកនាំប្រទេសតាមរយៈនៃការបោះឆ្នោតតាមពេលកំណត់ និងមិនក្លែងក្លាយព្រមទាំងស្មើភាពគ្នាថែមទៀតផង* " ។

គួររំលឹកថា មេដឹកនាំគណបក្សប្រឆាំងលោក *សម រង្ស៊ី* ធ្លាប់បានមានប្រសាសន៍នៅឯសន្និសីទកាសែតមួយកាលពីសប្តាហ៍កន្លងទៅនេះថា រដ្ឋាភិបាល នៃគណបក្សប្រជាជន *ហ៊ុន សែន* មិនហ៊ានអនុវត្តតាមកិច្ចព្រមព្រៀងក្រុងប៉ារីសឱ្យត្រឹមត្រូវនោះទេព្រោះខ្លាចការអនុវត្តគោលការណ៍ប្រជាធិបតេយ្យពិតប្រាកដនឹងធ្វើឱ្យគណបក្សនេះបាត់បង់អំណាច ។

នៅចំពោះមុខអ្នកកាសែតនោះ លោក *សម រង្ស៊ី* បានធ្វើសេចក្តីអធិប្បាយពន្យល់ហេតុផលជាច្រើនថាលទ្ធផលនៃការបោះឆ្នោតកន្លងទៅពោរពេញដោយភាពមិនប្រក្រតី ដូចជាការលួចបន្លំសន្លឹកឆ្នោតការលុបបំបាត់ឈ្មោះម្ចាស់សន្លឹកឆ្នោតជាជនជាតិខ្មែរដែលមិនបោះឆ្នោតឱ្យគណបក្សប្រជាជន ហើយអស់ទាំងនេះជាការអនុវត្តផ្ទុយនឹងគោលការណ៍លទ្ធិប្រជាធិបតេយ្យ ជាពិសេសផ្ទុយទៅនឹងខ្លឹមសារស្មារតីកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១ ។

ទាក់ទិននឹងលទ្ធផល នៃការបោះឆ្នោតថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ លោក *សម រង្ស៊ី* បានមានប្រសាសន៍ ថា "*បន្ទាប់ពីគណបក្សប្រជាជន ហ៊ុន សែន តាមរយៈ គ.ជ.ប បានលួចសន្លឹកឆ្នោតហើយ ឥឡូវគេចង់លួចយកកៅអីរបស់យើងទៀត* " ។ ការបោះឆ្នោតជ្រើសតាំងសភាជាតិអាណត្តិទី៤ដែលបានប្រព្រឹត្តទៅកាលពីចុងខែកក្កដា ត្រូវបានលោក *សម រង្ស៊ី* វិនិច្ឆ័យថា មានលក្ខណៈនៃការលួចបន្លំក្នុងកម្រិតជ្រុលហួសឆ្ងាយពីក្នុងឆ្នាំ១៩៩៨ដោយសារតែគណបក្សប្រជាជន *ហ៊ុន សែន* ចង់ឈ្នះខ្លាំងពេក ពីព្រោះតែខ្លាចចាញ់ ហើយក៏ធ្វើអ្វីៗជ្រុលជ្រួសហួសព្រំដែនទៅ ។

លោកបានបកអាក្រាតអំពីការលួចបន្លំសន្លឹកឆ្នោតតាមវិធីផ្សេងៗ រាប់ទាំងការបញ្ចេញទម្រង់១០១៨ដោយអាជ្ញាធរដែនដីរបស់គណបក្សប្រជាជនថ្នាក់ភូមិឃុំ ទៅឱ្យមនុស្សដែលមិនមានលក្ខណៈបោះឆ្នោតឱ្យបោះឆ្នោតឱ្យគណបក្សប្រជាជននៅពេលដែល គ.ជ.ប ក៏ដូចជាគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ខេត្ត-ក្រុង ឃុំ-សង្កាត់ បានឃុបឃិតគ្នាអនុវត្តផែនការលុបបំបាត់ឈ្មោះប្រជារាស្ត្ររាប់សែននាក់ដែលគេដឹងថា មិនបោះឆ្នោតឱ្យគណបក្សប្រជាជននោះ ។

ភាពមិនប្រក្រតីនៃការលួចបន្លំសន្លឹកឆ្នោតត្រូវបានលោក *សម រង្ស៊ី* លើកពន្យល់ដូចជានៅមួយការិយាល័យៗ មានការលួចបន្លំសន្លឹកឆ្នោតពី៣០ទៅ៥០ដែលអ្នកបោះឆ្នោតមានឈ្មោះស្ទួន ដដែលៗ ។

ប្រជាពលរដ្ឋខ្មែររាប់រយពាន់នាក់ដែលខកខានមិនបានបោះឆ្នោតបានសម្តែងនូវការសាទរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់មេដឹកនាំគណបក្សប្រឆាំងទាំងពីរដែលបានជម្រុញឱ្យបណ្តាប្រទេសជាហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសក្រឡេកមកមើលហេតុការណ៍ពិតនៅក្នុងប្រទេសកម្ពុជាដែលកំពុងតែធ្លាក់ចូលទៅក្នុងរបបផ្តាច់ការ ត្រួតត្រាដោយគណបក្សប្រជាជនកម្ពុជាជាបណ្តើរៗហើយ ៕

**តមកពីទំព័រ១ យ**

ឡើយ ។

មិនតែប៉ុណ្ណោះអំពើដ៏កម្រោលរបស់អាជ្ញាធរយួនទៅលើជនជាតិភាគតិចបានលេចឡើងនូវបញ្ហាធំៗចំនួនពីរនៅពេលដែលតំណាងអង្គការសមាគមខ្មែរកម្ពុជាក្រោមនៅក្នុងប្រទេសកម្ពុជា និងមូលនិធិកុលសម្ព័ន្ធភ្នំម៉ុងតាញ៉ាដែលមានមូលដ្ឋានធំនៅអាមេរិកបានស្នើយ៉ាងទទូចទៅកាន់ស្ថានទូតយួនប្រចាំក្រុងភ្នំពេញនិងសភាអឺរ៉ុបនៅទីក្រុងប្រ៊ុចសែល ។

អង្គការសមាគមខ្មែរកម្ពុជាក្រោមដែលរួមមានទាំងសហគមន៍ខ្មែរកម្ពុជាក្រោមរបស់លោក *ថាច់ សេដ្ឋា* ផងនោះបានសរសេរលិខិតមួយច្បាប់ផ្ញើទៅស្ថានទូតយួនកាលពីថ្ងៃអង្គារ ដោយបានស្នើសុំការអនុញ្ញាតឱ្យពួកគេបានទៅជួបលោក *ទីម សាខន* អតីតចៅអធិការវត្តភ្នំដិនខាងជើង ។ ហើយបើតាមការលេចព្ញ័ត៌មានមកនោះគឺលោក *ទីម សាខន* កំពុងមានជំងឺ និងត្រូវគេឃុំខ្លួនលោកនៅក្នុងផ្ទះទៀតផង ។

លិខិតនោះបានស្នើសុំអនុញ្ញាតឱ្យគណៈប្រតិភូអង្គការសមាគមខ្មែរកម្ពុជាក្រោមជួបលោក*ទីមសាខន* ដើម្បីបញ្ជាក់ការពិតឱ្យបានច្បាស់ ជៀសវាងការយល់ច្រឡំចំពោះទង្វើរបស់អាជ្ញាធរយួនកុម្មុយនីស្តទៅទៀត ។

យ៉ាងណាក៏ដោយ លោក *ថាច់ សេដ្ឋា* ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោមបានថ្លែងថាលោកកំពុងរង់ចាំការឆ្លើយតបពីស្ថានទូតយួន ព្រោះរហូតមកដល់ពេលនេះពុំទាន់មានចម្លើយគួរឱ្យទុកចិត្តណាមួយពីស្ថានទូតយួននៅឡើយទេ ។

លោក *ថាច់ សេដ្ឋា* បានមានប្រសាសន៍ថា "*ប្រសិនបើពុំមានការសម្ងាត់អ្វីពីស្ថានភាពរស់នៅរបស់លោក ទីម សាខនទេ គួរតែស្ថានទូតយួនអនុញ្ញាតឱ្យពួកយើងទៅជួបសួរសុខទុក្ខលោក ទីម សាខន ដោយផ្ទាល់ផង* " ។

មន្ត្រីអង្គការខ្មែរកម្ពុជាក្រោមមួយរូបទៀតបានលើកឡើងថា យើងមានការព្រួយបារម្ភពីសុខភាព និងសន្តិសុខផ្ទាល់ខ្លួនរបស់លោក*ទីមសាខន*ណាស់ ។ សំខាន់គឺយើងចង់ដឹងពីប្រវត្តិនៃការផ្សឹកនិងការដាក់ពន្ធនាគារលោកតែម្តង ព្រោះសំណើដែលយើងបានស្នើកាលពីមុនមកនោះ មិនទាន់បានទទួលនូវការឆ្លើយតបសោះ ។

ប៉ុន្តែបើសម្រាប់អ្នកនាំពាក្យក្រសួងមហាផ្ទៃឈ្មោះ *ខៀវ សុភ័គ* វិញ គាត់បាននិយាយតាមរបៀបគ្មានការឈឺឆ្អាលថា "*វាពិបាកណាស់ចំពោះអាជ្ញាធរកម្ពុជាក្នុងការធ្វើអន្តរាគមន៍នៅក្នុងករណីនេះ ដោយសារលោក ទីម សាខន កំពុងស្ថិតនៅក្នុងប្រទេសវៀតណាមហើយគាត់ក៏ជាជនជាតិវៀតណាមដែរ ពិសេសគឺនៅទីនោះមិនអាចមានសញ្ជាតិពីរបានទេ*" ។

ក្នុងនោះនៅក្នុងសុន្ទរកថាមួយដែលបានថ្លែងទៅកាន់សភាអឺរ៉ុប នៅអំឡុងសប្តាហ៍នេះលោក*កុក ខ្ស៊រ* ប្រធានមូលនិធិកុលសម្ព័ន្ធភ្នំម៉ុងតាញ៉ាបានអំពាវនាវឱ្យសហគមន៍អឺរ៉ុបជួយពង្រឹងសិទ្ធិមនុស្សនៅប្រទេសយួនដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងសេដ្ឋកិច្ចទ្វេភាគីថ្មីនៅពេលខាងមុខនេះ ។

បញ្ហាកុលសម្ព័ន្ធភ្នំម៉ុងតាញ៉ាហូរចូលប្រទេសកម្ពុជា ដើម្បីស្វែងរកឋានៈជាជនភៀសខ្លួនទៅកាន់ប្រទេសទី៣នោះកំពុងតែច្របូកច្របល់សម្បើមណាស់ដោយសារអាជ្ញាធរខ្មែរចេះតែចាប់ជនភៀសខ្លួនទាំងនោះបញ្ជូនទៅឱ្យអាជ្ញាធរយួនវិញ ។

មន្ត្រីនៃអង្គការការពារសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាបានជម្រុញឱ្យរដ្ឋាភិបាល *ហ៊ុន សែន*ព្យាយាមធ្វើការងារច្រើនទៀតដើម្បីការពារសមាជិកនៃសហគមន៍ខ្មែរកម្ពុជាក្រោម និងពួកកុលសម្ព័ន្ធភ្នំម៉ុងតាញ៉ាដែលស្វែងរកសិទ្ធិជ្រកកោននៅក្នុងប្រទេសកម្ពុជា ឬក៏ត្រូវឆ្លងទៅកាន់ប្រទេសទី៣នោះ ។

មន្ត្រីសិទ្ធិមនុស្សរូបនេះបានសង្កត់ធ្ងន់ថា "*រដ្ឋាភិបាលកម្ពុជាគួរតែអនុញ្ញាតឱ្យខ្មែរកម្ពុជាក្រោមនិងកុលសម្ព័ន្ធភ្នំម៉ុងតាញ៉ាស្នាក់នៅក្នុងប្រទេសកម្ពុជាផងវាប្រសើរជាងនិរទេសពួកគេត្រឡប់ទៅប្រទេសដែលពួកគេកំពុងតែមានបញ្ហានោះ* " ។

យើងគួរបញ្ជាក់ផងដែរថា មុនពេលករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តមសីហមុនីព្រះមហាក្សត្រខ្មែរយាងទៅបំពេញព្រះរាជទស្សនកិច្ចនៅប្រទេសយួនកាលពីអំឡុងខែមិថុនា ឆ្នាំ២០០៨កន្លងទៅនោះ លោក *ថាច់ សេដ្ឋា* នាយក

**តនៅទំព័រ៣ យ**

**តមកពីទំព័រ១ ក**

**ការនិយាយបែបនេះរបស់លោក ជាម យៀប ធ្វើឱ្យគេនឹកបារម្ភដល់ស្ថានភាពនៃការគ្រប់គ្រងប្រទេសរបស់គណបក្សប្រជាជនរយៈពេលច្រើនទសវត្សរ៍មកដល់ស្ថានភាពសព្វថ្ងៃនេះ ដែលធ្វើឱ្យប្រជារាស្ត្រទូទាំងប្រទេសជួបប្រទះនឹងការរំលោភសព្វបែបយ៉ាង ជាពិសេសបញ្ហាដីធ្លី ហើយដូច្នេះអាចនាំឱ្យប្រទេសនេះវិលទៅកាន់របបផ្តាច់ការដូលកាលអតីតកាល ។**

**នេះក៏គឺជាដើមហេតុនៃកង្វល់ដ៏សមរម្យរបស់សាធារណៈជន និងមន្ត្រីអង្គការសង្គមស៊ីវិលថា បើគណបក្សប្រជាជនកាន់អំណាចតែឯងបែបនេះតាមរបៀបជិះសេះលែងដៃ ធ្វើអ្វីៗតាមអំពើចិត្ត ហើយក៏នឹងមានការប្រើមុខតំណែងតួនាទីបំផ្លិចបំផ្លាញធនធានធម្មជាតិរបស់ប្រទេសបណ្តោយឱ្យមានអំពើពុករលួយ ឱ្យមានការឆក់ប្លន់ដណ្តើមយកដីធ្លីរបស់ប្រជារាស្ត្រនោះ មិនយូរទេរបៀបរបបគ្រប់គ្រងនឹងធ្លាក់ចូលក្នុងភាពអនាធិបតេយ្យ ហើយគណបក្សនេះនឹងប្រើប្រាស់កម្លាំងប្រដាប់អាវុធបែបពួកយោធាភូមា ដើម្បីបង្ក្រាបប្រជារាស្ត្រនោះ ។ តាមស្តាប់សម្តីរបស់មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនម្នាក់នេះបើប្រទេសកម្ពុជានៅតែស្ថិតក្រោមការត្រួតត្រារបស់បុគ្គលមុខដដែលបណ្តោយឱ្យមានអំពើពុករលួយដដែល បំផ្លាញធនធានធម្មជាតិដដែល ធ្វើឱ្យប្រជារាស្ត្ររងគ្រោះដដែល គឺ *ហ៊ុន សែន* ជានាយករដ្ឋមន្ត្រីនោះប្រទេសកម្ពុជាអាចនឹងក្លាយទៅជារបបផ្តាច់ការយោធាដូចប្រទេសភូមានោះហើយ ។**

**គណបក្សប្រជាជននេះមានប្រវត្តិធ្លាប់ដឹកនាំប្រទេសតាមបែបកុម្មុយនីស្តបណ្តោយឱ្យមានការជិះជាន់សង្កត់សង្កិនប្រជារាស្ត្ររហូតដល់តាំងខ្លួនធ្វើជាអ្នកសេរី ដើម្បីគ្រាន់តែឆក់ប្លន់ទ្រព្យសម្បត្តិរបស់រដ្ឋ និងរបស់រាស្ត្រទៅដាក់ក្នុងដៃមន្ត្រីដឹកនាំធំៗរបស់ខ្លួនប៉ុណ្ណោះ ។ ហើយវប្បធម៌អស់ទាំងនេះនៅតែជិតជាប់ក្នុងការឈឺចាប់របស់ប្រជារាស្ត្រខ្មែរដដែលបើទោះបីជាគណបក្សនេះដោយមានជំនួយពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ជាឧបករណ៍របស់ខ្លួន និងមានអាជ្ញាធរដែនដីជាដៃជើង របស់ខ្លួនអាចឆក់ប្លន់យកសន្លឹកឆ្នោតប្រជារាស្ត្របំបិទឈ្មោះប្រជារាស្ត្រ ហើយបំភ្លៃលទ្ធផលបោះឆ្នោតឱ្យគណបក្សនេះបានឡើងដល់៩០កៅអីនោះ ។**

**តើពាក្យថា សាកល្បង ចេញពីមាត់មន្ត្រីនយោបាយជាន់ខ្ពស់គណបក្សប្រជាជន ជាម យៀប អំពីគណបក្សនេះនឹងបន្តដឹកនាំប្រទេសក្នុងអាណត្តិទី៤នេះ ពាក្យសាកល្បងនេះមានអត្ថន័យយ៉ាងណា បើគណបក្សនេះធ្លាប់មានប្រវត្តិដឹកនាំប្រទេសឱ្យច្របូកច្របល់ និងធ្លាក់ចូលក្នុងដំណើរនៃគ្រោះថ្នាក់ដូចជាការរំលោភចូលយកដីធ្លីក្បែរព្រំដែនដោយប្រទេសជិតខាង និងការបង្ហូរចូលនូវជនអន្តោប្រវេសន៍យួនខុសច្បាប់ពេញស្រុកខ្មែរនោះ ?**

**បើអាណត្តិទី៤ នឹងជាការសាកល្បងរបស់រដ្ឋាភិបាលគណបក្សប្រជាជនតែឯងទៀតនោះ ច្បាស់ណាស់ថា នោះគឺជារូបភាពថ្មីនៃអំពើផ្តាច់ការពុករលួយនៅក្នុងប្រព័ន្ធរបបដែលគេកែកុនមុខមាត់លើរបៀបរបបគ្រប់គ្រងចាស់កាលសម័យកុម្មុយនីស្តសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរបបរដ្ឋកម្ពុជានោះហើយ ។ តើមានអ្វីជាការសាកល្បងថ្មីទៀតនោះ បើគណបក្សនេះជាគណបក្សដុះស្លែស្អុយឈ្មោះអំពីរឿងអំពើពុករលួយធ្វើឱ្យបាត់បង់ថវិកាជាតិមួយឆ្នាំៗជាង៥០០លានដុល្លារ ហើយក៏ឃើញតែពួកមន្ត្រីថ្នាក់ដឹកនាំធំៗរបស់គណបក្ស ទាំងក្នុងរដ្ឋាភិបាល ទាំងក្នុងសភាគ្រប់គ្នាក្លាយទៅជាអ្នកមានលើការរលាយធនធានរបស់ប្រទេសនិងភាពក្រីក្ររបស់ប្រជារាស្ត្រ ?**

**អ្វីដែលប្រជារាស្ត្រខ្មែរចងចាំមិនភ្លេចនោះគឺ មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជន ជាម យៀប ធ្លាប់បាននិយាយកាលមុនបោះឆ្នោតថា ពេលគណបក្សប្រជាជនឈ្នះដឹកនាំរដ្ឋាភិបាលអាណត្តិទី៤នោះ គណបក្សនេះនឹងរក្សាទុកកាស៊ីណូឱ្យនៅដដែល "ដើម្បីបង្កើនភាពក្រីក្ររបស់ប្រជារាស្ត្រ"(Sic!) ។ នេះមានន័យថា គណបក្សប្រជាជននឹងប្រើប្រាស់តួនាទី មុខតំណែងរបស់ខ្លួន ដើម្បីនឹងឆក់ប្លន់យកទ្រព្យសម្បត្តិទាំងអស់របស់ប្រជារាស្ត្រតាមដែលខ្លួនអាចធ្វើបានដើម្បីបង្កើនគំនរទ្រព្យសម្បត្តិរបស់ពួកខ្លួន ហើយដូច្នេះបង្កើនភាពក្រីក្ររបស់ប្រជារាស្ត្រនោះហើយ ។**

**ហ្នឹងហើយជានយោបាយនៃការសាកល្បងដាក់ប្រទេសកម្ពុជាទៅជាចំណាប់ប្រយោជន៍នយោបាយនៃមហិច្ឆតាអំណាចនិយមផ្តាច់មុខ លក់ស្រុក លក់ប្រទេស ដោយគណបក្សប្រជាជន ហ៊ុន សែន និងការជិះជាន់ធ្វើបាបប្រជារាស្ត្រគ្រប់ទីកន្លែងនោះ ។ របៀបនេះ រដ្ឋាភិបាលនេះមានតែដើរតាមផ្លូវផ្តាច់ការប្រើប្រាស់កម្លាំងប្រដាប់អាវុធក្នុងបំណងគម្រោងផែនការបង្ក្រាបប្រជារាស្ត្រមិនឱ្យធ្វើការរើបំរះតវ៉ារកសេរីភាព និងការប្រើប្រាស់សិទ្ធិជាម្ចាស់ប្រទេសតែប៉ុណ្ណោះ ។ វាគឺជាគំរូបែបផែនមួយនៃរបបគ្រប់គ្រងតាមបែបពួកយោធាផ្តាច់ការនៅប្រទេសភូមាដែលពិភពលោកកំពុងថ្កោលទោស ហើយដែលរដ្ឋាភិបាលកម្ពុជា ជាពិសេសគណបក្សប្រជាជន ហ៊ុន សែន ពេញចិត្ត ពេញថ្លើម និងតែងតែគាំទ្រចំពោះរបបផ្តាច់ការនោះផងដែរ៕**